វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ធនាគារ ANZ Royal


# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា*


ឆ្នាំ២០១០ លេខ ០២


## ការពង្រឹងវិស័យសំខាន់ៗ ដើម្បីសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ៖ កសិកម្ម និងការអភិវឌ្ឍជនបទ[1]

“កម្ពុជា ជាប្រទេសកសិកម្មមួយមានដី និងអាកាសធាតុអំណោយផលចំពោះផលិតផលកសិកម្ម... ប៉ុន្តែ កំពុងប្រឈមមុខនឹងបញ្ហា ដូចជា ការប្រកួតប្រជែង និងចំណងតភ្ជាប់នឹងទីផ្សារអន្តរជាតិ ជាដើម ។”

*លោកឧកញ៉ា ភូ ពុយ ប្រធានសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា*

### កសិកម្ម ៖ វិស័យមានកំណើនមិនទៀងទាត់

ដីមានជីជាតិល្អដ៏សំបូរ ព្រមទាំងអាកាសធាតុអំណោយផល ជួយឲ្យប្រទេសកម្ពុជា មានឧត្តមភាពប្រៀបធៀបក្នុងផលិតកម្មកសិកម្ម ។ នាបច្ចុប្បន្ន កសិកម្មបានក្លាយជាវិស័យជំរុញកំណើនមួយរបស់កម្ពុជា ។ ពីឆ្នាំ១៩៩៤-២០០៨ វិស័យកសិកម្ម កើនជាមធ្យមប្រហែល ៥% ក្នុងមួយឆ្នាំ (ក្រាហ្វិក ១) ។ តាំងពីដើមរៀងមក កំលាំងពលកម្មក្នុងស្រុកភាគច្រើនស្ថិតក្នុងវិស័យកសិកម្ម ប៉ុន្តែចំនួនភាគរយបានថយចុះមកត្រឹម ៥៦% ក្នុងឆ្នាំ២០០៧ ធៀបនឹង ៦៧% ក្នុងឆ្នាំ២០០២ ។

វិស័យកសិកម្ម មានចំណែកយ៉ាងសំខាន់ក្នុងកំណើនសេដ្ឋកិច្ច ប៉ុន្តែសក្តានុពលនៃវិស័យនេះ មិនទាន់បានប្រើប្រាស់ពេញលេញទេ ។ ពីឆ្នាំ១៩៩៤-២០០៨ កំណើនប្រចាំឆ្នាំជាមធ្យមនៃវិស័យឧស្សាហកម្ម និងសេវាកម្ម មានប្រហែល ១៥% និង ៩% ធៀបនឹង ៥% សម្រាប់កសិកម្ម (ក្រាហ្វិក ១) ។ ក្នុងអំឡុងពេលនោះដែរ ចំណែកវិស័យកសិកម្ម ក្នុង ផសស បានធ្លាក់ចុះពីប្រហែល ៥០% មកត្រឹម ២៥% រីឯឧស្សាហកម្ម កើនដល់ ២៨% និងសេវាកម្ម កើនដល់ ៣៩% ។ សារៈសំខាន់នៃវិស័យកសិកម្ម ស្តែងឡើងច្បាស់បំផុតក្នុងឆ្នាំ២០០៩ នៅពេលដែលវាជួយទប់ទល់ការធ្លាក់ចុះសេដ្ឋកិច្ច ។ ក្នុងបីឆ្នាំកន្លងទៅនេះ វិស័យកសិកម្មនៅតែមានកំណើនខ្ពស់ជាង ៥% ជានិច្ច នៅពេលដែលវិស័យឧស្សាហកម្ម និងសេវាកម្ម បានរួមចុះអស់ប្រហែល ៩,៥% និង ២% ។ ថ្លៃផលិតផលកសិកម្មខ្ពស់ជាងធម្មតា បានលើកទឹកចិត្តកសិករឲ្យខំដាំដុះច្រើនថែមទៀត ទោះបីមិនបានច្រើនដូចការរំពឹងទុកក្តី ។ ការឆក់ឱកាសល្អពេលទំនិញឡើងថ្លៃនេះ បានជួបឧបសគ្គនៃការឡើងថ្លៃធាតុចូល ចំណងទាក់ទងជាមួយទីផ្សារមានតិច និងកង្វះលទ្ធភាពទទួលបានឥណទានមានការប្រាក់ថោកសមរម្យ ។

ស្រូវជាផលដំណាំចំបងគេ ដោយតាំងពីដើមរៀងមក មានចំណែកលើសពី ៥០% ក្នុងផលដំណាំសរុប ។ ចាប់តាំងពីឆ្នាំ១៩៩៤ មក ផលិតកម្មស្រូវបានកើនឡើងបីដងដោយសារកំណើនផលិតភាព និងផ្ទៃដីដាំដុះ ធ្វើឲ្យកម្ពុជាមានស្រូវអង្ករគ្រប់គ្រាន់សម្រាប់ខ្លួនឯងនៅឆ្នាំ១៩៩៥ និងមានលទ្ធភាពនាំចេញអតិរេកស្រូវអង្ករក្នុងឆ្នាំបន្ទាប់ៗទៀត ។ ពីឆ្នាំ១៩៩៤-២០០៧ ផ្ទៃដីដាំដុះកើនឡើងប្រហែល ៣៣% ហើយកម្ពុជា មានអត្រាកំណើនទិន្នផលស្រូវជាមធ្យមខ្ពស់

១ សង្ខេបចក្ខុវិស័យ លេខ២ បូកសរុបបទបង្ហាញ និងការពិភាក្សាផ្សេងៗក្នុងវគ្គទី ៣ក(i) នៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១០ ។ វាគ្មិនក្នុងវគ្គនេះមាន៖ លោកឧកញ៉ា ភូ ពុយ ប្រធានសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា និង បណ្ឌិត តុង គីងស៊ិន អ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI ។


* ផ្អែកលើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១០:
ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

ជាងគេនៅក្នុងតំបន់ ។ នៅឆ្នាំ២០០៨ ផលិតកម្មស្រូវកើនដល់ប្រហែល ៧លានតោន ។

ផលិតកម្មស្រូវមានកំណើនមិនទៀងទាត់ទេ ហើយនៅដើមសហស្សវត្សថ្មីនេះ វាបានប្រែប្រួលជាខ្លាំង (ក្រាហ្វិក ២) ។ ទិន្នផលស្រូវកម្ពុជា នៅតែមានកម្រិតទាបបំផុតក្នុងតំបន់ ទោះបីបានកើនឡើងយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំនេះក្តី ។ ពីឆ្នាំ១៩៩៤-២០០៨ ទិន្នផលស្រូវជាមធ្យមនៅកម្ពុជា កើនដល់ ២,១៧តោន/ហិកតា ធៀបនឹង ៤,៣៧តោន/ហិកតា នៅថៃ ២,៦៤តោន/ហិកតា នៅវៀតណាម និង ៣,០៥តោន/ហិកតា នៅឡាវ ។

សមត្ថភាពកិនស្រូវមានកំរិត ក៏ជាឧបសគ្គដល់ការនាំចេញអង្ករពីកម្ពុជាដែរ ។ កម្ពុជា បានបាត់បង់ឱកាសរកចំណូលបានច្រើនថែមទៀតពីការនាំចេញ ដោយសារតែការនាំចេញជាស្រូវបែបនេះ (នាំចេញជាផ្លូវការ និងក្រៅផ្លូវការ) ទៅប្រទេសជិតខាង ហើយប្រទេសគេក៏កិនវាចេញជាអង្ករ ។ ពីឆ្នាំ២០០០-២០០៨ បរិមាណអង្ករនាំចេញជាផ្លូវការក្នុងមួយឆ្នាំ មានជាមធ្យមត្រឹមតែ ១% នៃអតិរេកស្រូវសរុបប៉ុណ្ណោះ ។ ក្នុងឆ្នាំ២០០៨ កម្ពុជាអាចទទួលបានចំណូលជាផ្លូវការរហូតដល់ ១០៨៩លានដុល្លារ ថែមទៀតប្រសិនបើអតិរេកស្រូវទាំងអស់ ត្រូវបាននាំចេញតាមច្រកផ្លូវការ (ក្រាហ្វិក ៣) ។[២] បញ្ហាចំបងមួយទៀតគឺ អង្ករកម្ពុជាដែលនាំចេញមានគុណភាពអន់ជាងគេ ដូច្នេះ ថ្លៃលក់បានក៏ចុះទាបតាមនោះដែរ ។

## ឧបសគ្គរាំងកំណើនកសិកម្ម ៖ ករណីស្រូវ/អង្ករ

ផលិតភាពស្រូវ កំណត់ឡើងដោយកត្តាជាច្រើន ។ កត្តាសំខាន់ៗ រួមមាន ៖ ទំហំដីដាំដុះ សន្តិសុខដីធ្លី ធាតុចូល

ក្រាហ្វិក ១៖ អត្រាកំណើនពិតប្រចាំឆ្នាំតាមវិស័យ (គិតជា%)




ប្រភព: NIS Handbook of Statistics (2006, 2008)

២ ដោយសារ ពាណិជ្ជកម្មស្រូវឆ្លងកាត់ព្រំដែនជាលក្ខណៈក្រៅផ្លូវការមានទ្រង់ទ្រាយធំ មួយភាគធំនៃចំណូលសរុប ប្រហែលទទួលបានតាមរយៈពាណិជ្ជកម្មក្រៅផ្លូវការ ។

គ្រប់គ្រាន់និងមានគុណភាព ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កំរិតបច្ចេកវិទ្យា និងលក្ខខណ្ឌអាកាសធាតុ ។

យោងតាមសេដ្ឋកិច្ចមាត្រដ្ឋាន ទំហំដីដាំដុះធំតែងពាក់ព័ន្ធនឹងប្រសិទ្ធភាពផលិតកម្មខ្ពស់ ។ ក្នុងករណីប្រទេសកម្ពុជា ដែលកសិករភាគច្រើនគ្មានដីធ្លី ឬមានដីតូច (ពោលគឺ កសិករមានដី ឬដាំដុះលើផ្ទៃដីតូចជាង ១ហិកតា) លទ្ធផលអង្កេតបង្ហាញថា ដីទំហំតូច មានប្រសិទ្ធភាពជាងដីទំហំធំ ។ ប៉ុន្តែគួរឲ្យស្តាយ កសិករនៅតំបន់ជនបទភាគច្រើន ត្រូវប្រឈមនឹងបញ្ហាអសន្តិសុខដី ដោយសារពុំមានប្លង់កម្មសិទ្ធិដីនៅក្នុងដៃ ។ សម្បទានដីសេដ្ឋកិច្ចអាចបង្កើនការនាំចេញ និងផលិតកម្មកសិកម្មបានយ៉ាងច្រើន ប៉ុន្តែដីជាច្រើនដែលបានផ្តល់រួចហើយ សព្វថ្ងៃនៅមិនទាន់ប្រើប្រាស់ ឬប្រើប្រាស់មិនទាន់បានពេញកម្លាំងនៅឡើយទេ ។

ការប្រើធាតុចូលមិនគ្រប់គ្រាន់ និងមិនមានប្រសិទ្ធភាព ក៏នាំឲ្យផលិតភាពស្រូវធ្លាក់ចុះដែរ ។ ថ្លៃដីខ្ពស់បានរារាំងដល់ការប្រើជីនៅកម្ពុជា ហើយការប្រើជីមិនទៀងទាត់ និងមិនត្រឹមត្រូវ ធ្វើឲ្យផលស្រូវជាសក្តានុពលថយចុះ ។ ហេដ្ឋារចនាសម្ព័ន្ធ ថាមពល មានការអភិវឌ្ឍតិចតួចនៅឡើយ ធ្វើឲ្យអគ្គិសនីមានថ្លៃខ្ពស់ខ្លាំង និងក្លាយជាឧបសគ្គចំបងមួយ ចំពោះការធ្វើអាជីវកម្មនៅកម្ពុជា ។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ មានស្ថានភាពប្រសើរជាងមុន ដោយសារការស្តារជួសជុល និងការសាងសង់ថ្មី ប៉ុន្តែនៅមានការងារត្រូវធ្វើជាច្រើនទៀត ដើម្បីឲ្យកម្ពុជាដើរទាន់ប្រទេសជិតខាង លើផ្នែកគុណភាពហេដ្ឋារចនាសម្ព័ន្ធ ។ ទាក់ទិននឹងកំរិតបច្ចេកវិទ្យាវិញ មានកសិករខ្មែរតិចនាក់ទេ ដែលមានលទ្ធភាពប្រើប្រាស់គ្រឿងម៉ាស៊ីនកសិកម្មទំនើប ដូចជា ត្រាក់ទ័រ ជាដើម ។ កម្ពុជា សំរេចបានការរីកចំរើនខាងបច្ចេកវិទ្យាតិចតួចណាស់ ។ ជាទូទៅលក្ខខណ្ឌអាកាសធាតុនៅកម្ពុជា មានលក្ខណៈអំណោយផល ។ គ្រោះមហន្តរាយខាងអាកាសធាតុមិនសូវមានទេ ប៉ុន្តែលក្ខខណ្ឌអាកាសធាតុមិនប្រក្រតី ដូចជា ការរាំងស្ងួតយូរពេល ឬខុសខែ និងភ្លៀងធ្លាក់ច្រើនពេកជាដើម បានកើតមានឡើងនាពេលថ្មីៗ និងបានប៉ះពាល់ដល់ផលប្រមូលបាន ។

## គោលនយោបាយកសិកម្ម៖ បច្ចុប្បន្ន និងអនាគត

ការពង្រីកវិស័យកសិកម្ម ជាសសរទ្រូងនៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ដែលជាគ្រឹះនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០០៦-២០១០ ។ NSDP ឆ្នាំ២០០៩-២០១៣ បន្តផ្តល់អាទិភាពលើការបង្កើនផលិតភាពកសិកម្ម ការធ្វើពិពិធកម្មកសិកម្ម និងការជំរុញកសិ-ឧស្សាហកម្ម ។ ផែនការនេះ ក៏ផ្តោតកាន់តែ

ច្រើនលើយុទ្ធសាស្ត្របង្កើនផលិតផលសំរេច តាមការបង្កើនសកម្មភាពផលិតកម្មលើដីធ្លីដែលមានស្រាប់ ជាជាងការពង្រីកផ្ទៃដីដាំដុះ ។

ដើម្បីអាចទាញយកចំណេញឲ្យបានពេញលេញ ពីសក្តានុពលនៃកសិកម្ម ឧបសគ្គធំៗដែលរារាំងផលិតកម្មត្រូវតែដោះស្រាយឲ្យបាន ។ ទាំងស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាល ត្រូវធ្វើការរួមគ្នាដើម្បីសំរេចការងារនេះ ។ គេបានរកឃើញថា គំរោងអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាលតែឯង មិនអាចជួយកែលំអផលិតភាពបានច្រើនទេ ។

ស្រូវ/អង្កររបស់កម្ពុជា មានគេយកចិត្តទុកដាក់ច្បាស់ណាស់ ឲ្យតែអាចធានាគុណភាព និងការផ្គត់ផ្គង់បាន ។ ដូច្នេះ ការប្រឹងប្រែងដោះស្រាយឧបសគ្គដើម្បីកែលំអផលិតភាពអង្ករ ពិតជាអាចនាំមកនូវផលចំណេញភ្លាមៗ និងច្រើនណាស់សំរាប់កម្ពុជា ។ ការបំបាត់ឧបសគ្គទាំងនេះ អាចបង្កើនផលិតភាពស្រូវរហូតដល់ ៣តោន/ហិកតា នៅឆ្នាំ ២០១៣ និងធ្វើឲ្យផលិតកម្មស្រូវកើនទ្វេដង ។

ការងារដ៏ចាំបាច់មួយ គឺត្រូវដោះស្រាយបញ្ហាអសន្តិសុខដី ដែលចោទឡើងជាយូរមកហើយនៅពាសពេញប្រទេស ។ ការផ្តល់សន្តិសុខដីធ្លីជូនដល់កសិករ នឹងលើកទឹកចិត្តពួកគេឲ្យធ្វើវិនិយោគបន្ថែម និងបង្កើនផលិតភាព ។ កិច្ចប្រឹងប្រែងរបស់ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋាភិបាល ក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងការដោះស្រាយវិវាទ មិនត្រូវផ្អាកដំណើរការទេ ។ ការផ្តល់សម្បទានដីខ្នាតតូចទៅឲ្យអ្នកគ្មានដីធ្លី ក៏ត្រូវបង្កើនឡើងដែរ ។

ការបង្កើនទាំងបរិមាណ និងគុណភាពអង្ករ ត្រូវមានការកែលំអវិធីធ្វើកសិកម្ម ។ ការកែលំអរបៀបជ្រើសរើសគ្រាប់ពូជ ការដាំដុះ ការច្រូតកាត់ និងបច្ចេកទេសស្តុក ឬទុកដាក់ វាជួយធានាដល់ទិន្នផលខ្ពស់ និងស្រូវអង្ករមានគុណភាពល្អ ។ ប្រជាកសិករ តែងពិបាកនឹងបោះបង់ចោលរបៀបរបបជាប្រពៃណីក្នុងការធ្វើស្រែចំការណាស់ ដូច្នេះ ត្រូវមានការអប់រំ ការបញ្ចុះបញ្ចូល ការបង្ហាញជាក់ស្តែងពីរបៀបធ្វើកសិកម្មបែបទំនើប និងការបណ្តុះបណ្តាល ។ សេវាផ្សព្វផ្សាយបច្ចេកទេស និងការផ្តួចផ្តើមគំនិតកសាងសមត្ថភាព ត្រូវបង្កើនថែមទៀត ដើម្បីពង្រីកការយល់ដឹង និងការទទួលយករបៀបធ្វើកសិកម្មបែបទំនើប ។ រដ្ឋាភិបាលគួរផ្តួចផ្តើមគំនិតបង្កើតកសិដ្ឋាន ឬមន្ទីរពិសោធន៍សំរាប់ការបន្សុទ្ធគ្រាប់ពូជ ការបង្កាត់ពូជ និងការរក្សាទុកគ្រាប់ពូជ ។ ទាំងស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋាភិបាល ត្រូវតែបន្តជួយទ្រទ្រង់ដល់កសិដ្ឋានឯកជន និងប្រឹងប្រែងជួយម្ចាស់ដីតូចៗឲ្យកាន់តែមានលទ្ធភាព ទទួលបានកំចីមានការប្រាក់ទាប ដើម្បីពួកគាត់អាចធ្វើវិនិយោគដោយខ្លួនឯង ទៅលើផលិតកម្ម ។ កំចីមានកាលកំណត់ខុសៗគ្នា ត្រូវតែបង្កើតឡើង សំរាប់ផ្តល់ឲ្យកសិករទៅតាមសមត្ថភាពទូទាត់សងរបស់កសិករម្នាក់ៗ ។

ក្រាហ្វិក ២៖ សន្ទស្សន៍ផលិតកម្មស្រូវ ( ១៩៩៦=១០០ )




ប្រភព៖ ការគណនាផ្អែកលើ NIS Handbook of Statistics ( 2006, 2008 )

ក្រាហ្វិក ៣៖ សក្តានុពលនាំចេញអង្ករ




ប្រភព៖ MoEF; NIS Handbook of Statistics 2008

ក្រៅពីអង្ករ ការជំរុញវិស័យនេសាទ និងកសិ-ពាណិជ្ជកម្ម ក៏ជាផ្នែកមួយសំខាន់បំផុតក្នុងគោលនយោបាយខាងកសិកម្មផងដែរ ។ វិស័យនេសាទ តែងត្រូវគេមើលរំលងជារឿយៗ ដែលនាំឲ្យខាតបង់អស់ច្រើនណាស់ ។ ពិនិត្យតាមសក្តានុពលបំរើការនាំចេញ វិស័យនេសាទគួរទទួលបានអាទិភាពស្មើគ្នានឹងផលិតកម្មផលដំណាំ ។ ការចាប់យកចំណែកទីផ្សារពិសេសមួយសំរាប់ផលនេសាទ ជាបញ្ហាប្រឈមមួយធំណាស់ ដែលត្រូវមានការឃោសនាផ្សព្វផ្សាយជំរុញវាឡើង ។ ម្យ៉ាងទៀត សមត្ថភាពនៃឧស្សាហកម្មកែច្នៃម្ហូបអាហារ និងវេចខ្ចប់ក្នុងស្រុកត្រូវតែពង្រឹងបន្ថែម ដើម្បីបំពេញបានតាមស្តង់ដារអន្តរជាតិ ។ ដូច្នេះ ទាំងផ្នែកសាធារណៈ និងផ្នែកឯកជន ត្រូវផ្តល់ជំនួយគាំទ្រជាធនធានហិរញ្ញវត្ថុ និងវិនិយោគច្រើនថែមទៀតដល់កសិ-ឧស្សាហកម្ម ។

ថ្លៃថាមពលខ្ពស់នៅកម្ពុជា ជាពិសេសអគ្គិសនីបានរារាំងដល់ការប្រើប្រាស់វាក្នុងវិស័យកសិកម្ម ។ ការបញ្ចុះ

ថ្លៃអគ្គិសនី ទាមទារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពល ។ ក្រុមហ៊ុនឯកជនដែលមានសមត្ថភាពវិនិយោគខ្ពស់ គួរទទួលបានការអនុញ្ញាតឲ្យផលិតអគ្គិសនីដោយខ្លួនឯង ព្រមទាំងអាចលក់អគ្គិសនីទៅឲ្យតំបន់ជិតខាង ។ ការជួយទ្រទ្រង់ថ្លៃអគ្គិសនីជាបណ្តោះអាសន្ន ក៏ទំនងជាចាំបាច់ដែរ សំរាប់ការកសាងឧស្សាហកម្មកែច្នៃស្រូវអង្ករ ។ ថ្លៃអគ្គិសនីពិសេស គួរដាក់អនុវត្តនៅថ្ងៃឈប់សំរាក និងថ្ងៃចុងសប្តាហ៍ ។ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ក៏ត្រូវអភិវឌ្ឍន៍យ៉ាងឆាប់ហ័សដែរ ។ សរុបមក ការកសាងហេដ្ឋារចនាសម្ព័ន្ធជួយឲ្យកសិករអាចឆ្លើយតបនឹងតម្រូវការទីផ្សារ បានទាន់ពេលវេលា ។ កសិកម្មប្រកបដោយចីរភាព ក៏ទាមទារការការពារគុណភាពទឹក និងដី តាមរយៈការគ្រប់គ្រងទឹក និងដីឲ្យបានកាន់តែប្រសើរ ។ យុទ្ធសាស្ត្រនេះ អាចជួយឲ្យកសិករប្រឈមមុខនឹងគ្រោះរាំងស្ងួត និងកាត់បន្ថយចំណាយលើធាតុចូល ។

រដ្ឋាភិបាល ត្រូវជួយដល់វិស័យឯកជនក្នុងការស្វែងរកគោលដៅនាំចេញថ្មីៗ ។ ការទទួលបានលទ្ធភាពចូលទៅកាន់ទីផ្សារអង្ករនៅប្រទេស ហ្វីលីពីន ឥណ្ឌូនេស៊ី និងសហភាពអឺរ៉ុប ជាកំលាំងជំរុញមួយធំណាស់ សំរាប់ឧស្សាហកម្មស្រូវអង្ករនៅកម្ពុជា ។

ការលើកកំពស់ការសម្រួលខាងពាណិជ្ជកម្ម អាចជួយសម្រួល និងពង្រឹងពាណិជ្ជកម្មអង្ករថែមទៀត ។ ការចាប់យកទីផ្សារនាំចេញថ្មីៗ ទាមទារការធ្វើឲ្យនីតិវិធីផ្សេងៗកាន់តែសាមញ្ញ និងការកាត់បន្ថយចំណាយជាផ្លូវការ និងក្រៅផ្លូវការ លើប្រតិបត្តិការពាណិជ្ជកម្ម ។ ថ្លៃការចូលចតនៅផែ និងការដឹកជញ្ជូនតាមនាវានៅកម្ពុជា ក៏ខ្ពស់ខ្លាំងជាងគេដែរ ដូច្នេះ ត្រូវតែបញ្ចុះថ្លៃខ្លះ ដើម្បីជំរុញការនាំចេញអង្ករតាមផ្លូវទឹក ។

វិបត្តិកន្លងមកមានចំណុចល្អមួយ ដោយបានជួយពង្រឹងឆន្ទៈនយោបាយក្នុងការអភិវឌ្ឍកសិកម្ម និងអភិវឌ្ឍជនបទ ។ នៅកម្ពុជា ប្រជាជនក្រីក្រភាគច្រើនរស់នៅតំបន់ជនបទ ដែលពឹងផ្អែកជាសំខាន់ទៅលើកសិកម្ម ដូច្នេះមានតែការតស៊ូស្វិតស្វាញអនុវត្តសមាសភាគនេះ នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិប៉ុណ្ណោះទេ ដែលអាចធ្វើឲ្យកំណើនប្រកបដោយសមធម៌ក្លាយជាការពិត ។




## ឯកសារពិភាក្សា លេខ ៤២

### ការដឹកនាំនៅថ្នាក់ភូមិ ឃុំ នៅប្រទេសកម្ពុជា៖ ការសិក្សាពីការដឹកនាំនៅក្នុងឃុំ បី នៃខេត្ត បី

ធន់ វិមាលា, អ៊ូ ស៊ីវហួច, អេង នេត្រា និង លី តឹម

ដោយសន្មតថាមានគំលាតរវាងរដ្ឋ-សង្គម ការសិក្សានេះព្យាយាមកំណត់ពីប្រភេទផ្សេងៗ នៃអ្នកដឹកនាំនៅមូលដ្ឋាន ក្នុងនេះមានទាំងអ្នកដឹកនាំជានារីផង និងចរិតលក្ខណៈរបស់ពួកគេ ក៏ដូចជាសមាសធាតុនៃភាពពេញសិទ្ធិ ដើម្បីរកមើលថា តើពួកគេអាចជួយតភ្ជាប់គំលាតខាងលើបានឬទេ និងតាមរបៀបណា ។

គេរកឃើញថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានជួយតភ្ជាប់គំលាតរវាងរដ្ឋ និងសង្គម បើទោះជាវាមានលក្ខណៈយឺតយ៉ាវ មិនស្មើភាព និងតូចចង្អៀតក្តី ។ ការសិក្សា មានលើកឡើងនូវគោលនយោបាយពាក់ព័ន្ធមួយចំនួន ដើម្បីជួយដល់កំណែទម្រង់នេះ និងជំរុញរបបប្រជាធិបតេយ្យ ។


អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
(៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh, website: http://www.cdri.org.kh